# ការសម្ភាសន៍របស់អ៊ុំប្រុស ទឹម ប៉ែនរិទ្ធី

**កៈ អ្នកសម្ភាសន៍ឈ្មោះ ហោង សុវណ្ណានរិន្ទ** **ខៈ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ ទឹម ប៉ែនរិទ្ធី**

## ពត៍មានសង្ខេបរបស់អ៊ុំប្រុស ទឹម ប៉ែនរិទ្ធី

អ៊ុំប្រុសទឹម ប៉ែនរិទ្ធីមានអាយុ៧៣ឆ្នាំហើយឆ្នានេះ ហើយគាត់មានស្រុកកំណើតនៅខេត្ត កំពង់ស្ពឺ។ សព្វថ្ងៃគាត់មានកូន៣នាក់ ប្រុស២ ស្រី១ ហើយគាត់ក៏មានចៅផងដែរ មានចៅស្រី៥ និងចៅប្រុស១។ គាត់បានឆ្លងកាត់រឿងលំបាកជាច្រើនកាលពីសម័យប៉ុល ពត គាត់ធ្លាប់ធ្វើការជាច្រើនដើម្បីបានបបរ និង បាយហូបចិញ្ចឹមក្រពះនាសម័យនោះ។

កៈ បាទជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់អ៊ុំដែលបានឲ្យខ្ញុំសម្ភាសន៍ពីប្រវិត្តរបស់អ៊ុំហើយការសម្ភាសន៍ណឹងត្រូវបានរៀបចំដោយសាកលវិទ្យាល័យមួយដែលមានឈ្មោះថា Brigham Young University ដែលនៅឯសហរដ្ឋអាមេរិក។ បាទ គោលបំណងរបស់សាកលវិទ្យាល័យគឺចង់សម្ភាសន៍ប្រវិត្តប្រជាជនខ្មែរ ដើម្បីរក្សារទុកប្រវិត្តប្រជាជនខ្មែរដើម្បីឲ្យកូនចៅជំនាន់ក្រោយរបស់អ៊ុំអាចស្គាល់ពីប្រវិត្តរបស់ជីដូនជីតារបស់ពួកគេហើយរៀនអំពីប្រវិត្តរបស់ពួកគេណាអ៊ុំ បាទហើយចឹងនៅពេលដែលខ្ញុំសម្ភាសន៍អ៊ុំចប់ ខ្ញុំនឹងដាក់ការសម្ភាសន៏របស់អ៊ុំណឹងនៅក្នុងវេបសាយរបស់សាលាដែលមានឈ្មោះថា www.cambodiaoralhistory.byu.edu ណាអ៊ុំចឹងតើអ៊ុំយល់ព្រមឲ្យខ្ញុំដាក់សម្ភាសន៍របស់អ៊ុំចូលទៅក្នុងវេបសាយរបស់សាលាទេអ៊ុំ?

ខៈ ឲ្យតើ។

កៈ បាទចឹងសម្រាប់ថ្ងៃខែដែលខ្ញុំសម្ភាសន៍នេះគឺ នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០២០ ហើយការសម្ភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិធ្លោកអណ្តូង ឃុំស្លរក្រាមស្រុកសៀមរាប ខេត្តសៀមរាបណាអ៊ុំ ហើយខ្ញុំជាអ្នកសម្ភាសន៍ឈ្មោះហោង សុវណ្ណានរិន្ទ អញ្ចឹងខ្ញុំចង់សួរអ៊ុំថា អ៊ុំមានឈ្មោះពេញអ្វីដែរអ៊ុំ?

ខៈ ឈ្មោះទឹម ប៉ែនរិទ្ធី។

កៈ ហើយអ៊ុំមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ ហៅក្រៅ ហៅកង ម៉ុន។

ក៖ មានតែមួយណឹងទេឬមានទៀតអ៊ុំ?

ខ៖ មានទៀតមាន សឿន សារុនមួយទៀត។

ក៖ អ៊ុំមានរហ័សនាមច្រើន?

ខ៖ ជំនាន់ណឹងជំនាន់លាក់ខ្លួនលាក់នេះ។

ក៖ ចុះឆ្នាំនេះអ៊ុំមានអាយុប៉ុន្មានឆ្នាំហើយអ៊ុំ?

ខ៖ ៧៣ឆ្នាំហើយ។

ក៖ តើអ៊ុំមានថ្ងៃកំណើតនៅថ្ងៃខែឆ្នាំកំណើតដែរអ៊ុំ?

ខ៖ ថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៥០។

ក៖ ចុះអ៊ុំចាំឆ្នាំខ្មែរថាកើតឆ្នាំណាទេអ៊ុំ?

ខ៖ ឆ្នាំខ្មែរ ឆ្នាំខាល ខែចែត្រ។

ក៖ ចុះអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខ៖ ស្រុកកំណើតនៅខេត្តកំពង់ស្ពឺ។

ក៖ តើអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខ៖ បងប្អូន៥នាក់។

ក៖ អ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ កូនពៅគេ។

ក៖ ចឹងអ៊ុំអាចប្រាប់ឈ្មោះទាំងអស់របស់បងប្អូនអ៊ុំបានទេតាំងពីបងគេមកដល់អ៊ុំ?

ខ៖ កង ឃុត បងកង ស៊ុក នៅរស់ បងកង សុខស្លាប់ជំនាន់អាពត បងកង ខន ស្លាប់ជំនាន់អាពត ហើយនិងខ្លួនខ្ញុំ។

កៈ ចុះអ៊ុំមានចាំសាច់រឿងអ្វីខ្លះជាមួយបងប្អូនរបស់អ៊ុំ តាំងពីក្មេងៗមកអ៊ុំ? តើបទពិសោធន៍អ្វីខ្លះដែលអ៊ុំបានចងចាំជាមួយពួកគាត់ដែរ?

ខៈ បងប្អូនខ្ញុំមិនដែលបានចេះឈ្លោះគ្នាទេ បើនិយាយទៅខ្ញុំមិនសូវបាននៅជុំគ្នាដែរព្រោះដើរចោលស្រុក ហើយបងក៏ដើរទៅធ្វើការនៅតែបងស្រីអីចឹងណា ហើយធ្វើការមានធ្វើអីធ្វើស្រែធ្វើអីចឹងទៅ ហើយខ្ញុំនៅរៀនរហូតដល់រៀនហើយខ្ញុំបានបួសមួយឆ្នាំចេញពីបួសមកបានទៅធ្វើទាហាន ណឹងហើយធ្វើទាហានពីឆ្នាំ៧០ ដល់៧៣ដាច់អាពតណឹង អាពតចូលមកគេជម្លៀសយកមកនៅបាត់ដំបង មកធ្វើការឲ្យគេបើនិយាយទៅមិនមែនជាកម្មករទេអាណឹងគេហៅគេកម្មករដាច់ថ្លៃ ដូចដាច់ថ្លៃរបស់វាចឹងឯងធ្វើគ្មានពេលសម្រាកទេ សម្រាកពេលយប់បានបន្តិចបន្តួចជួនកាលឡើងពីធ្វើការចឹងទៅអត់មានបាយក៏មាន ម្នាក់ៗនៅជំនាន់ក្បាលជង្គង់វាធំជាងអីទាំងអស់ ចង់ធំជាងក្បាល ហើយស្គមគ្មាននេះទេដើរសឹងតែខ្យល់បករលំណឹងណាជំនាន់ណឹងអត់មានអ្នកណាត្រូវទាស់អីទេវាអត់ឲ្យស៊ីម៉ងណាជួនកាលគ្នា១០០នាក់អង្ករ២កំប៉ុង ១០០នាក់អង្ករ២កំប៉ុងហើយធ្វីអាធ្វីបន្លារវាកាត់មកអត់មានបេះបន្លារទេអត់មានដើមតូចៗទេ យកអាដើមធំចញ្រាំដូចដាក់ឲ្យជ្រូកចឹងឯង ស៊ីមិនស្រួលមុតមាត់ ថ្ងៃមួយយកអាចានចោះគូទតិចដាក់ទៅហើយយកធ្នឹលត្រងពីក្រោមយកទឹកដល់ពេលសល់អង្ករពីគ្រាប់ពេលបាយគឺថាវេទនាណាស់ក្មួយអើយជួនកាលអត់ចឹងទៅជួនកាលបានចឹងទៅ ជួនកាលបើខែច្រូតហើយបានកន្លះខែដែរគ្រាន់ហូបបាយពេញបានឆ្អែតណឹងកន្លះខែរួចពីណឹងទៀតហើយហើយជំនាន់ណឹងគឺថាអាក្មេងតូចៗពួកវាណឹង វាប្រើយើងដូចកញ្ចោះដាច់ថ្លៃចឹងណាអត់មានពេលសម្រាករបៀបម៉េចអត់មានទេ គឺឡើងពីស្រែចឹងទៅ ទៅលើកប្រឡាយលើកប្រឡាយណឹងរហូតដល់ម៉ោង១០យប់បានចូលមកដេក ដេកតិចពេលម៉ោង៣ ម៉ោង៤ណឹង ម៉ោង៤ណឹងភ្ញាក់ទៅភ្ជួរទៀតហើយ ណឹងខែវស្សាខែប្រាំងក៏ធ្វើចឹងដូចគ្នាបើមិនភ្ជួរស្រែនេះទេគឺលើកទំនប់រែកដី ហើយរែកដីសុទ្ធតែដាក់ផែនការណ៍ មួយការ៉េមួយគឺបចឹងទៅ ទាល់តែមួយយប់មួយគឺបណឹងចង់ដាច់ខ្យល់មិនមែននេះទេរែកមួយម៉ែត្រ៤ជ្រុងណឹងរែកៗ គេដាក់ផែនការណ៍ចឹងតែរែកអស់ហើយគេដាក់ថែមទៀតហើយ តែហើយមុនអាផែនការណ៍ណឹងវាថែមទៀតទាល់តែរែកអូសក្រឡា បើរែកអូសក្រឡាអត់ហើយត្រូវតែរែកឲ្យហើយណឹងចុះម៉ោង៥ ម៉ោង៦ចឹងណាយើងចូលធ្វើការហើយប្រសិនជាយើងធ្វើមិនទាន់ទេរហូតដល់ឧទាហរណ៍គេយប់ម៉ោង១០ចឹង យើងទាល់តែម៉ោង១១ ម៉ោង១២អីបានហើយ រែកម៉េចធ្វើឲ្យហើយណាគេមិនឲ្យយើងនេះទេព្រោះគេដាក់ផែនការណ៍ណឹង។

កៈ ចុះម៉េចកាលណឹងអ៊ុំចូលធ្វើទាហានដែរអ៊ុំ?

ខ៖ ទាហានពេលណឹង មុនចូលធ្វើទាហានណឹងជំនាន់លន់ណុលបានចាញ់ខ្មែរក្រហមណឹង សឹងពីបួសមកទៅធ្វើទាហានប៉ាដោយណឹងឯង ហើយទាល់តែយើងនិយាយពីជំនាន់អាពត វិញគឺថាវេទនាណាស់មិនមែននេះទេ មួយៗដាច់ពោះងាប់ស្លាប់ច្រើនគឺអត់បាយណឹងម៉ងវា បង្អត់ម៉ងណឹងណា ហើយពួកវាវិញវាស៊ីពេញៗឆ្អែតៗវាស៊ីឆ្អែតរបស់វា វាលួចដាំគេដឹងថាវា លួចក៏គ្មានអ្នកណាធ្វើអីវាដែរគ្នាវាវាស៊ីឆ្អែតទៅក៏យើង ដូចខ្ញុំថាចឹងគ្នា១០០នាក់បបរ២កំប៉ុងអី ក៏មានដែរមួយថ្ងៃជាមួយផ្ទីបន្លារ ឥឡូវនិយាយអីទៀត។

ក៖ បាទអ៊ុំ កាលពីនៅក្មេងអ៊ុំធ្លាប់មានពេលវេលាលេងអ្វីដែរជាមួយបងប្អូនរបស់អ៊ុំ?

ខ៖ ទេដូចមិនដែលបានលេងអីទេមានតែទៅសាលារៀនលេងបាល់លេងអីចឹងទៅហើយបង ប្អូនខ្ញុំអត់បាននៅនៅតែបងស្រីជាមួយបងស្រីចឹងណា បងៗខ្ញុំគាត់ទៅរៀនជួនកាលគាត់បួស ចឹងទៅគាត់ទៅរៀននៅបាត់ដំបង ទៅរៀននៅភ្នំពេញអីចឹងណា។

ក៖ ចុះម្ដាយរបស់អ៊ុំគាត់មានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ម្ដាយឈ្មោះ អ៊ុំ ណយ ឪពុក កង ឃិត។

ក៖ តើចុះម្ដាយគាត់កើតនៅថ្ងៃខែឆ្នាំដែរអ៊ុំ?

ខ៖ អត់ចាំទេ។

ក៖ ចុះឆ្នាំខ្មែរវិញគាត់ឆ្នាំណាដែរអ៊ុំ? អ៊ុំចាំទេ?

ខ៖ យីដូចអត់ចាំដែរខ្ញុំ ម្ដាយខ្ញុំស្លាប់ខ្ញុំនៅបួសហើយគាត់ស្លាប់ជំនាន់អាពតដែរណឹង ទៅវាអត់ ចាំកាលណឹង ឪពុកគាត់ស្លាប់មុខអាពត បងស្រីបងអីគាត់ស្លាប់នៅជំនាន់អាពតទាំងអស់ បើ និយាយទៅវាច្រើនដែរណឹងទាំងក្មេងតូចៗទាំងក្មួយទាំងអី។

ក៖ ចុះម្ដាយអ៊ុំមានស្រុកកំណើតនៅឯណាដែរអ៊ុំ?

ខ៖ នៅបែកចានខេត្តកណ្ដាល។

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំ គាត់កាច ឬក៏ស្លូតដែរអ៊ុំ?

ខ៖ ម្ដាយខ្ញុំស្លូតគាត់មិនកាចទេ ស្លូតហើយកាលនេះណឹងគាត់នៅបែកចាន ដល់ឪពុករបស់ គាត់ត្រូវជីតារបស់ខ្ញុំណឹងគាត់ទៅធ្វើចៅហ្វាយស្រុកនៅកំពង់ស្ពឺណឹងទៅតាមក៏នៅធ្វើភូមិធ្វើ កំណើតអីនៅណឹងទាំងអស់ទៅ។

ក៖ ចុះអ៊ុំចងចាំសាច់រឿងអ្វីខ្លះដែរទាក់ទងជាមួយនិងម្ដាយរបស់អ៊ុំ? តាំងពីក្មេងមកអ៊ុំចាំសាច់អ្វីខ្លះដែរពីគាត់?

ខ៖ គាត់មិនមានរឿងអីត្រូវនេះទេ តែប្ដីប្រពន្ធគាត់គាត់មិនដែលឈ្លោះគ្នាផង

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ប្រកបមុខរបរអ្វីដែរដើម្បីចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ គឺមេផ្ទះ គាត់មិនដែលនេះអីទេ គាត់មេផ្ទះតែជំនាន់ណឹងគាត់មានចំការនេះទៅគាត់លក់អុស លក់អីឲ្យគេអ្នកឡើងត្នោតអីណឹងណា។

ក៖ ចុះម្ដាយរបស់អ៊ុំគាត់ធ្លាប់សាច់រឿងកាលពីក្មេងៗរបស់គាត់មកកាន់អ៊ុំទេ? គាត់ធ្លាប់និយាយថាកាលពីគាត់នៅក្មេងៗម៉េចៗ?

ខ៖ អត់ដែល។

ក៖ អ៊ុំអត់ចាំថ្ងៃខែឆ្នាំកំណើតរបស់ឪពុកអ៊ុំទេចឹង?

ខ៖ អត់ទាំងអស់។

ក៖ អញ្ចឹងឪពុករបស់អ៊ុំគាត់កើតនៅខេត្តកណ្ដាលដែរមែនអ៊ុំ?

ខ៖ នៅខេត្តកំពង់ស្ពឺ។

ក៖ ចុះឪពុករបស់អ៊ុំគាត់ជាមនុស្សបែបណាដែរអ៊ុំ? គាត់ស្លូត ឬក៏គាត់កាចដែរអ៊ុំ?

ខ៖ ឪពុកខ្ញុំស្លូតណាស់ គាត់អត់កាចទេបើគាត់កាចមានហេតុផលរបស់គាត់ព្រោះគាត់ប្រដៅកូនឲ្យចេះគាត់ប្រដៅថាកុំឲ្យមានការលោភលន់ខ្លាំង ឲ្យប្រឹងតែរៀនសូត្រទៅហើយជំនាន់ណឹងគេថាកៅអីរដ្ឋមន្ត្រីគេមានអស់ហើយរៀនឲ្យបានតែសញ្ញាប័ត្រយកមកព្យួរជញ្ជាំងទៅ មានតែប៉ុណ្ណឹងឯងចាស់ៗពីដើមមានទៅថាអី រកស៊ីទៅ។

ក៖ ចុះឪពុករបស់អ៊ុំគាត់ប្រកបមុខរបរអ្វីដែរដើម្បីចិញ្ចឹមជីវិត?

ខ៖ មានតែធ្វើស្រែចំការ ធ្វើតែស្រែធ្វើតែចំការ។

ក៖ ចុះឪពុករបស់អ៊ុំគាត់ធ្លាប់ប្រាប់សាច់រឿងរបស់គាត់កាលពីនៅក្មេងៗដល់អ៊ុំទេ?

ខ៖ គាត់អត់ដែលមាននិយាយអីគាត់គ្រាន់តែប្រាប់ថាអារឿងតាំងពីគាត់កំព្រារនៅតែ២នាក់បងប្អូនណឹង គាត់កំព្រារនៅតែ២នាក់បងស្រីគាត់រហូតគេនៅចិញ្ចឹមដូចជានៅជាមួយតាចឹងទៅ គាត់ថាកាលដែលបានគ្នាជាមួយម្ដាយខ្ញុំណឹងដោយសារនេះទៅក៏ជីតារបស់ខ្ញុំណឹងក៏យកឪពុករបស់ខ្ញុំណឹងយកមកការឲ្យផងណឹងគាត់មានអីគាត់អត់ដែរជំនាន់ណឹង យកមកការឲ្យទៅក៏។

ក៖ ចុះយាយខាងម្ដាយរបស់អ៊ុំគាត់មានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ឈ្មោះយាយប៉ុម បើជីតាខាងម្ដាយឈ្មោះតាអ៊ុំ។

ក៖ ចុះពួកគាត់មានស្រុកកំណើតនៅខេត្តកណ្ដាលទាំងអស់គ្នាដែរមែនអ៊ុំ?

ខ៖ គាត់នៅខេត្តកណ្ដាលជីតាឪពុកម្ដាយរបស់ខ្ញុំណឹងណា នៅខេត្តកណ្ដាលនៅឯបែកចាន។

ក៖ តែអ៊ុំអត់ចាំថ្ងៃខែឆ្នាំកំណើតរបស់គាត់ទេ?

ខ៖ អត់ទេយូរហើយ។

ក៖ ចុះតាខាងឪពុកវិញ?

ខ៖ អត់ អត់ដែលដឹងអត់ម៉ង។

ក៖ អរចឹងខាងឪពុកអ៊ុំអត់ដឹងទេ?

ខ៖ អត់ដឹងទេ ចុះបើគាត់កំព្រារតាំងពីតូចមកនោះ។

ក៖ ចុះអ៊ុំធ្លាប់រស់នៅខេត្តណាខ្លះដែរតាំងពីក្មេងមកដល់ឥឡូវនេះអ៊ុំ?

ខ៖ ធ្លាប់នៅខេត្តកំពង់ស្ពឺណឹងឯង ហើយនៅជំនាន់ប៉ុល ពតណឹងមកនៅខេត្តពោធិ៍សាត់ណឹងហើយ ដល់ចេញពីពោធិ៍សាត់ណឹងដាច់ពីអាពតបានទៅកំពង់ស្ពឺវិញណឹង។

ក៖ ចុះអ៊ុំមានបងប្អូន ឬសាច់ញាតិដែលរស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ អត់មានទេ។

ក៖ ចុះភរិយារបស់អ៊ុំគាត់មានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ ឈ្មោះទុំ សារ៉ែន។

ក៖ អញ្ចឹងអ៊ុំបានរៀបអាពាហាណ៍ពិពាហាណ៍ជាមួយភរិយានៅឆ្នាំណាដែរអ៊ុំ?

ខ៖ នៅឆ្នាំ១៩៧៣។

ក៖ ឆ្នាំ១៩៧៣ ណឹងអត់ទាន់ប៉ុល ពតអាហីអ៊ុំ?

ខ៖ ប៉ុល ពតហើយ រៀបនៅអាពតណឹងឯងអ៊ុំហ្អែង មានប្តីមានប្រពន្ធរៀងខ្លួនគេក៏ងាប់ប្តីនៅអាពតណឹង ខ្ញុំក៏ងាប់ប្រពន្ធនៅអាពតណឹងបានគេរៀបឲ្យ អង្គរគេរៀបឲ្យចឹងទៅ។

ក៖ ចុះកាលប៉ុល ពតណឹង អ៊ុំនៅខេត្តណាដែរអ៊ុំដែអ៊ុំរៀបអាពាហាណ៍ពិពាហាណ៍ណឹង?

ខ៖ នៅពោធិ៍សាត់នេះ ជម្លៀសពីកំពង់ស្ពឺមក។

ក៖ ដើររហូតមែនអ៊ុំកាលណឹង ឬក៏ម៉េចដែរអ៊ុំ?

ខ៖ គេដឹកឡានមុខដំបូងគេដឹកឡានពីកំពង់ស្ពឺនិងមិនចោលនៅកំពង់ឆ្នាំង ទម្លាក់នៅកំពង់ឆ្នាំងបានឡើងរទេះភ្លើងមកដល់ពោធិ៍សាត់បានចុះពីត្រឹមពោធិ៍សាត់ណឹងគេដាក់ឡានយកទៅទម្លាក់ចោលនៅថ្មល់បត់បានចុះទៅត្បូងទៀតទៅឯស្រុកប្រវឹកណោះ។

ក៖ ចឹងអ៊ុំរៀបអាពាហាណ៍ពិពាហាណ៍ណឹងរៀបចំឡើងដោយសម័យប៉ុល ពតមែនអ៊ុំ?

ខ៖ ប៉ុល ពត ចាប់ដៃគ្នាគ្មានអីរៀបទេគេថាចាប់ដៃគ្នាដឹងតែប្តីប្រពន្ធគ្នាចឹងទៅ។

ក៖ ចុះកាលណឹងបើគេឲ្យយើងរៀបចឹងយើងអាចបដិសេធបានអត់អ៊ុំ?

ខ៖ អត់ទេតែគេថាឲ្យរៀបហើយអត់មានបដិសេធបានទេ។

ក៖ ចុះបើបដិសេដគេអាចយកទៅកសាងទេអ៊ុំ?

ខ៖ យកទៅកសាងអីយកទៅវៃចោលម៉ងណា។

ក៖ ចុះអ៊ុំធ្លាប់ស្គាល់អ៊ុំស្រីពីមុនទេមុនចាប់ដៃគ្នាណឹង?

ខ៖ អត់ទេ អត់មានដែលស្គាល់ស្គាល់តែពេលនៅសហាករណ៍ជាមួយគ្នាទេស្គាល់គ្នាទៅណាបើពីមុនៗមកមិនដែលស្គាល់អីគ្នាអត់ទេគាត់នៅភ្នំពេញ។

ក៖ ចុះអ៊ុំចេះអាន និង ចេះសរសេរអក្សរខ្មែរទេអ៊ុំ?

ខ៖ ចេះ។

ក៖ ចុះកាលណឹងអ៊ុំរៀននៅសាលាណាដែរអ៊ុំ?

ខ៖ នៅសាលាបឋមសិក្សាវត្តត្រពាំងគងហើយនៅអឺ...ថ្នាក់ទី៨វាចូលបឋម អនុវិទ្យាល័យ ចង់ភ្លេចដែរហើយ។

ក៖ ចុះអ៊ុំមានចេះភាសាអ្វីផ្សេងក្រៅពីភាសាខ្មែរយើងទេ?

ខ៖ អត់ទេ។

ក៖ អត់បានរៀនភាសាបារាំងអីទេអ៊ុំ?

ខ៖ អក្សរបារាំងរៀនបានតិចដែរចាប់ផ្ដើមរៀននៅថ្នាក់ទី១០ អីថ្នាក់ទី១១ រៀនថ្នាក់ទី១១ ថ្នាក់ទី៩ ទៅវាចោលយូរណាកាលណឹងបើវានិយាយទៅនេះដែរណឹងគ្រាន់ថាយើងចោល យើងអាចមើលដាច់អក្សរអីមើលដាច់ ជាអក្សរឡាតាំងឡាអីយើងអាចសរសេរបានណាអក្សរសរសេរឈ្មោះសរសេរអី។

ក៖ ចុះអ៊ុំមានមិត្តភក្តិស្និតស្នាលដែលធំធាត់មកជាមួយគ្នាទេអ៊ុំ?

ខ៖ ស្លាប់អស់ហើយបាត់អស់ហើយជំនាន់។

ក៖ ចុះពួកគាត់ដែលស្និតស្នាលជាមួយអ៊ុំណឹងគាត់មានឈ្មោះអ្វីដែរអ៊ុំ?

ខ៖ អឺ បើនិយាយទៅវាច្រើនដែរណឹងជំនាន់ធ្វើទាហានណឹងមានច្រើនណាស់មិត្តភក្តិកូនចៅហើយមកជំនាន់អាពតណឹងក៏មានច្រើនដល់តែមកបែកគ្នាអស់ទៅវាភ្លេចទាំងឈ្មោះទៀតពេលបែកគ្នា។

ក៖ ចុះអ៊ុំមានអនុស្សាវរីយ៍អ្វីដែរជាមួយមិត្តភក្តិដែលស្និតស្នាលណឹងអ៊ុំ?

ខ៖ អនុស្សាវរីយ៍បើជំនាន់អាពតវិញបានមានច្រើន ជួនកាលគេបានលួចពោតលួចដំឡូងអីបានចេះតែចែកគ្នាហូបអីចឹងណាហើយខ្ញុំមិនដែលទៅលួចអីគេទេតែគ្រាន់ថាគេអាពួកម៉ាកណឹងវាចេះទៅលួចចេះទៅ មានប្រវិត្តមួយទៅលួចដំឡូងគេចុះកាលណឹងគេឲ្យឃ្វលគោមួយក្រោលណឹង១០០នឹមនោះ។

ក៖ ១០០នឹម វា២០០គោ ហើយម្នាក់ឯងអ៊ុំ?

ខ៖ ២នាក់ណឹងហើយ ២នាក់ចឹងហើយ ហើយទៅដាច់នៅក្នុងព្រៃណាមិនមែននៅនេះទេដាច់ដោយឡែក ការដ្ឋានគេនៅឆ្ងាយចឹងយើងនៅក្នុងព្រៃតែ២នាក់ទេ ធ្វើក្រោលធ្វើរោងមួយណឹងយប់ឡើងទៅលួចដំឡូងគេអាមួយនោះប៉ុនខាងលួចថ្ងៃណឹងទៅជាមួយគ្នារាល់ដងអត់ដែលទៅទេទើបតែទៅថ្ងៃណឹងម្ដងទេ ដលទៅៗលួចបានកន្លះការ៉ុងម្នាក់អាបាវឆ្នុតណាអាបាវគេចាក់ក្រថៅកន្លះបាវណឹងវាកន្លះបាវខ្ញុំកន្លះបាវលីមកដល់កាយអាចម៍គោកប់ កប់អាចម៍គោទល់ព្រលឹមឡើងណឹងពីការដ្ឋានស្រែខាងក្រោមនោះគេឡើងមកយកអាចម៍គោ១០០រទេះមិនដឹងគិតម៉េចទេអញកាយគេមកដល់ឈឹបៗទៅគេមកយកអាចម៍គោឯងអុញ។

ក៖ គេយកអស់ទៅ?

ខ៖ អឺបើពួកកម្មាភិបាលវាឃើញងាប់ណាជូនអីវាកាយៗជិតដល់អាអាចម៍គោណឹងអាណឹងវាឃ្លានបានវាដើរទៅកន្លែងការដ្ឋានវាទៅ មានអីពួកអាររទេះណឹងហៅគ្នាយើងមកចែក២ដុំ ២ដុំ៣ដុំម្នាក់ចឹងទៅដាក់គេយកដាក់រទេះរាងខ្លួនអស់ទៅយើងរួច ហីបើសិនជាវាដឹង។

ក៖ ឲ្យតែវាដឹងថាយើងលួចអីហ្វបដឹងតែពួកវាសម្លាប់ចោលមែនអ៊ុំ?

ខ៖ ណឹងហើយគេយកទៅសម្លាប់ចោលតើឲ្យតែគេដឹងឲ្យតែគេចាប់បានអត់មានភស្តុតាងទេកាលពីជំនាន់ណឹង ដល់វាជិតចប់ក៏វាចង់យកទៅវៃចោលដែរពួកម៉ាកខ្ញុំ៥នាក់មើលក្របី ថ្ងៃណឹងក្របីកើតមកវាមិនអត់ឲ្យកូនវាបៅប្រាប់ទៅចេះតែប្រាប់កម្មាភិបាល កម្មាភិបាលណឹងហ្មែងមើលៗម៉េចបានវាមិនឲ្យបៅ ទល់ក្របីណឹងកូនក្របីណឹងងាប់លីយកមកដាក់ការដ្ឋានទៅដាក់ការដ្ឋានទាល់នេះទៅគេចោទយើងថាយើងសម្លាប់កូនក្របី យើងអត់បានសម្លាប់ទេមានណាពួកយើង៥នាក់ណឹងគេដកឲ្យទៅកាប់ឈើដល់កាប់ឈើទៅហើយអាមួយនោះពួកម៉ាក់ខ្ញុំដែរតែវាកម្មាភិបាលវានេះណាគេមូលដ្ឋាន តែគ្រាន់តែថាវាមូលដ្ឋានមិនមែនមូលដ្ឋានចំទេអាណឹងដូចប្រពន្ធវានៅមូលដ្ឋានចឹងណាបងប្អូនគេនៅមូលដ្ឋានទៅណឹងយួនជិតចូលហើយយួនចូលហើយណា ដល់គេនេះទៅគេទទួលថ្ងៃណឹងយួនវៃចូលវៃដល់នេះហើយណឹងដល់ស្វាយដូនកែវហើយណឹង ដល់ចឹងអាពួកទ័ព្វណឹងវាដូចឧបមាវាយកយើងទៅសម្លាប់ចឹងណាវាមានកម្លាំងវានៅនោះត្រៀមហើយស្រេចហើយ អានាក់នាំមានមេអាពួកគេកងមេអីគ្រាន់តែនាំទៅទេ ដល់ទទួលថ្ងៃណឹងអាវាវៃដល់ស្វាយដូនកែវវាទាញអាកម្លាំងវាមកទប់នៅស្វាយដូនកែវអស់ទៅ ទៅដល់នោះពួកខ្ញុំគ្នាច្រើន ពួកអាមកពីស្វាយរៀងនោះ១៧នាក់ ខ្ញុំណោះ៥នាក់ហើយមុនគេប្រាប់យើងណឹងកាំបិត ពូថៅអីគេយកអស់រលីងហើយ ដកគេមកដកពីផ្ទះយើងអស់រលីងហើយអត់ថ្មានស្អីទេ គេដកទៅគេប្រាប់ថាចុះឲ្យខ្ញុំទៅកាប់ឈើចុះទៅកាប់អីទៅបើយកពូថៅកាំបិតខ្ញុំអស់ហើយអីនៅខាងលើនោះវាមិនខ្វះទេ ដល់នេះទៅបានអាពួកម៉ាកមួយអាណឹងអាណឹងចាមវាវៃកាំបិតដំកាំបិតអានោះវាធ្វើកាំបិតវាមុតៗណាស់មុនណឹងទៅណឹង

ដើរទៅវា វាថាអើយហ្មាមិនកើតទេហ្អែងយកកាំបិតអញមួយទៅ អានោះកាំបិតវាសំលាងមុត ណាស់វាថាហ្អែងកុំភ័យហាសបើតដៃម្នាក់បាន២នាក់អីទៅកុំឲ្យគេធ្វើងាប់ទទេ បានអាកាំបិត ណឹងមួយទៅ ទៅវាចេះមើលមុខឯងភ្លឺសៗអានាក់នាំទៅ ដល់នេះទៅអាកម្លាំងនោះដកអស់ ទៅនេះវាដាក់បាយឲ្យអានេះវាសរសេរសំបុត្រមួយ ឲ្យអាមួយថាមូលដ្ឋានណឹងណាឲ្យវាកាន់ ដល់ចឹង វាថាមើលហាសដល់ដើរដាច់ឆ្ងាយពីនេះទៅ មើលហាសបើកមើល អេបើកម៉េច ហាស អឺអញអ្នកបើកបើកទៅ បើកមើលចុះវាអត់ចេះអក្សរអានោះ ដល់មើលទៅគេថាសម្មាក់ មិត្តពើនចាំទទួល៥នាក់នេះទុកផងចាំខ្ញុំមានផែនការណ៍ចាំខ្ញុំទៅយកវិញ ឯងថាអីយ៉ាអានេះ ដល់ហើយតើយើងចេះតែប្រយ័ត្នចឹងដែរណា ដល់ទៅដល់បាន៥ ៦ថ្ងៃយួនដេញទម្លាក់ពីលើភ្នំ មកវិញ ដល់ធ្លាក់មកវិញមកនៅចំការ មកនៅចំការអា៤នាក់នោះវាយកទៅទាល់តែបានយក ទៅត្រជាក់ចិត្តនោះ ដល់នេះទៅមានអីចុកពោះ ចុកពោះកោសខ្យល់ផងអីផងគេអឺយកអាប្អូន នាក់នេះទៅមុនទៅហើយចាំទៅក្រោយគេ បានតែប៉ុណ្ណឹងស្អែកខានស្អែកឡើង មកគេឲ្យមក នេះមកយកស្រូវយកអង្ករអីទៅនៅជិតក្រឡោនភ្លូកនេះ ទៅដល់ជាន់ៗយួនបាញ់អាដេកា ចេញពីស្វាយដូនកែវមកវើធឹងៗនាំគ្នារត់ឡើងលើ រត់តាតាត់តាយាយអូបែកអុំហ្អែងណឹងឈឺអុំ ហ្អែងណឹងពេលរត់ពុងតែឈឺទៀតហើយគេឲ្យថាមាននេះអី គោមួយនឹមម្នាក់ អុំហ្អែងមួយនឹម អុំមួយនឹម ដល់នេះទៅអុំហ្អែងឈឺអាកម្មារភិបាលគេថា ហ្អែងទៅៗចាំអញដាក់ប្រពន្ធហ្អែង តាមរទេះអញឲ្យប្រពន្ធហ្អែងជិះរទេះ ឯងបានចឹងបានគេដាក់ចឹងក៏ជិះទៅអូសរទេះអូសគាវ មួយដាក់អង្ករដាក់អីបានបន្តិតចទៅមកដល់ត្រង់នេះបាត់ប្រពន្ធមួយយប់ អឺម៉េចហើយទេវើយ បានបបួលពួកម៉ាកបងប្អូននៅជាមួយណឹងគេជូនមកយកដាក់អង្រឹងដាក់អីមកសែងព្រោះឈឺ នោះ មកដល់គេដើរបានចុះអាពួករត់ពីលិចមកក៏មកនៅណឹងមិនមែននៅម្នាក់ឯងណាដាក់ ទៅដេកណឹងដែរដល់មកនាំគ្នាចាប់ជ្រូកសែងជ្រូកវិញទៅអុំហ្អែងដើរទៅដើរចឹងទៅទៅដល់ នេះ ទៅដល់នោះគេចាប់ផ្តើមមែនទែនហើយ ចាប់ផ្តើមអាពួកកម្មារភិបាលណាវាគៀង វាគៀង យើងឲ្យឡើងទៅភ្នំនោះដល់ពួកខ្ញុំប៉ុន្មាននាក់ប្រហែលជា៩ ១០រទេះ អត់ទៅទេវើយកុំទៅតោះ កាំបិតរៀងខ្លួនសំលាងឲ្យមុតៗ ដល់នេះទៅអាពួកណឹងវាហៅថាទៅនេះទៅឯណោះទៅដល់ ភូមិដំណាក់ទ្រព្យ ទៅដល់ភូមិដំណាក់ទ្រព្យណឹងវាមកទៀតហើយដល់មកទទួលអាពួកនៅ ស្វាយរៀងណា ពួកស្វាយរៀងដែលវានៅសល់ប៉ុន្មាននាក់ដែរវាសម្លាប់អត់អស់នោះដល់នៅ រស់ទៅគេជួបបងប្អូនគេអាពួកបងប្អូនគេធ្វើទ័ព្វ ធ្វើទ័ព្វខាងបូព៌ា មកដល់អានោះសួរម៉ែឪវានៅ ឯណាបងប្អូនវានៅឯណានៅឯណាហាសបើគេសម្លាប់ចោលអស់ហើយណឹង អានោះចាប់ផ្តើ ប៉ះបោរបណ្តោយ ប៉ះបោររត់ដេញបាញ់អាពួកម្មារភិបាល អាកម្មារភិបាលនៅខាងយើងទេ ណាមិនមែនបាញ់លើអាពួកនេះទេណា ដល់ពួកអាណឹងឈ្លោះគ្នារត់រប៉ាត់រប៉ាយអស់ទៅខ្ញុំប្រុ ចឡើងមកព្រៃយាងនេះកន្លែងយើងឈប់ទិញដូងនោះរត់មកណឹង នៅណឹងមួយឆ្នាំបានធ្វើ ស្រែចែកគេឯងណឹងនេះហើយបានទៅស្រុកទៅ ចឹងបានថាប្រវត្តិជូរចត់ណាស់ជំនាន់អាពត

មិនមែនអ្នករស់ណឹងសុទ្ធតែឆ្អឹងដែកស្បែកស្ពន់ហើយបានរត់បាននោះ ជីវិតថ្លៃបើចូលពេទ្យចូលពីមុខចេញពីក្រោយហើយអត់មានរឿងចូលពីមុខចេញពីមុខទេតែចេញពីមុខចូលក្រោយសែងទៅក្រោយណឹងហើយ ងាប់អើយថា បើនិយាយពីនេះសារដើមមកដំបូងបន្តិចទៅដល់ដំបូងគេទៅដល់សហាករណ៍ណឹងដំបូងណាទើបទៅដល់អឺ...នេះគេឲ្យនៅកងស្នែងសែងខ្មោចទៅកប់ណឹងណា មានអាអ្នកចាំកាប់រណ្ដៅហើយមានអាអ្នកសែងមនុស្សស្លាប់រាល់ថ្ងៃដើរស៊ឹងតែអស់ជើងតែសែងមិនសូវឆ្ងាយប៉ុន្មានដែរ វាសែងចេញតែកន្លែងសហាករណ៍តិចទៅណឹង។

កៈ អ្នកស្លាប់ណឹងភាគស្លាប់ដោយសារអ្វីដែរអ៊ុំ?

ខៈ អត់ម្ហូបអត់បាយម៉ងណាអត់បាយហូបណាគ្មានស្លាប់ពីអីទេគ្មានជំងឺអីទេ ស្លាប់ដោយសារអត់បាយម៉ង ដូចគាត់អ្នកចេញទៅពីភ្នំពេញកម្ររស់ណាស់គឺថាគ្មាអត់ដែលលំបាកនោះអ្នកនៅផ្សារ កូនចិនកូនអី ថាងាប់នោះងាប់ មួយថ្ងៃណឹងសែងគ្នា៤ ១០នាក់តគ្នារហូត ជួនកាលអាខ្លះកូនងាប់ចឹងទៅអត់ប្រាប់គេទេសុខចិត្តអារសាច់កូនស៊ីណា អារទៅស្ងោរទៅស្ងោរទៅដល់គេដឹងគេយកម៉ែឪណឹងទៅសម្លាប់ចោលទៀតទៅ បានថាអូ!។

កៈ ឃើញថាឃោរឃៅមែនទែន ចុះអ៊ុំធ្លាប់ប្រកបមុខរបរអ្វីខ្លះដែរដើម្បីរកប្រាក់ចំណូលចិញ្ចឹមគ្រួសារដែរអ៊ុំ?

ខៈ តាំងពីដើមមកមិនដែលមានធ្វើអីទេធ្វើតែទាហាន ធ្វើទាហានណឹងមកតែកាលមុនធ្វើទាហានណឹងយើងធ្វើស្រែធ្វើអីចឹងទៅណាធ្វើតែស្រែចឹងទៅ ហើយរួចធ្វើស្រែចឹងទៅយើងដើររកការងារធ្វើ ធ្វើផ្ទះធ្វើអីចឹងទៅកំប៉ិកកំប៉ុកបានលុយណឹងទៅ ហើយនិងមើលថែចំការអុសកុំឲ្យគេកាប់អីចឹងទៅយើងយកមកលក់នៅពេលគេឡើងត្នោតទៅគេទិញម៉ៅចំការយើងទៅណា។

កៈ ចុះអ៊ុំធ្លាប់ប្រកបមុខរបរលក្ខណៈគ្រួសារទេអ៊ុំ? ដូចជាចិញ្ចឹមគោ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់អីទេអ៊ុំ?

ខៈ អត់ទេ បើថាលក្ខណៈគ្រួសារនេះទៅវាជ្រូកមួយ ពីរ មាន់៤ ៥ អីទៅមាននៅផ្ទះពីដើមមានទុកជាម្ហូបខ្លួនយើងទៅជួនកាលដោះស្រាយយកមាន់ទៅលក់បានលុយខ្លះចឹងដែរណា។

កៈ តាំងពីក្មេងរហូតមកដល់ពេលនេះតើជីវិតរបស់អ៊ុំមានការផ្លាស់ប្ដូរអ្វីខ្លះដែរអ៊ុំ?

ខៈ ណឹងហើយនិយាយពីការផ្លាស់ប្ដូរណឹងវាផ្លាស់ប្ដូរច្រើនដែរណឹងណា ទាល់តែយើងមានកូនមានចៅអីចឹងមកយើងបានធូរតិចហើយ បើមិនទាន់មានកូនធំវានៅតូចៗ យើងខំប្រឹងរក

ចិញ្ចឹមចិញ្ចឹមអីចឹងយើងលំបាកដែរណឹងណា ហើយដល់ឥឡូវយើងបានកូនធំជុំមានការងារធ្វើអីចឹងយើងវាធូរដែរទៅ។

ក៖ ចុះពេលវេលាណាដែលអ៊ុំគិតថាជាពេលវេលាដែលអ៊ុំពិបាកជាងគេ ក្នុងជីវិតពេលណាដែរអ៊ុំ?

ខ៖ ពិបាកជាងគេនៅជំនាន់អាពតណឹងឯងដែលពិបាកជាងគេបំផុត ជំនាន់អាពតណឹងបើជំនាន់យើងនៅនេះលក្ខណៈគ្រួសារយើងជាសេរីគឺវាអត់មានពិបាកអីមកពិបាកជំនាន់នោះឯង។

ក៖ ចុះពេលវេលាណាដែលអ៊ុំគិតថាជាពេលវេលាដែលអ៊ុំសប្បាយចិត្តជាងគេក្នុងជីវិត?

ខ៖ ពេលវេលាសប្បាយពីក្មេងមកចេះតែមានចឹងទៅមានពេលបុណ្យទានអីចឹងយើងចេះតែសប្បាយដើរលេងដើរអីនិងគេទៅចឹងណា ហើយទៅការងារយើងចិញ្ចឹមជីវិតចេះតែទៅរកតោះ តោះយើងទៅ។

ក៖ តាំងពីក្មេងមកតើអ៊ុំមានក្ដីស្រម៉ៃចង់ធ្វើអ្វីទេពេលធំឡើងអ៊ុំ?

ខ៖ ហ្អេជំនាន់ណឹងបើនេះទៅបើថាយើងនៅរៀនចេះសង្ឃឹមខំប្រឹងរៀនទៅក្រែងលោរបានធ្វើការខាងក្រុមហ៊ុនខាងគេរើសអីចឹងទៅធ្វើបានតែដល់ហើយអត់បានរៀន ហើយប្រទេសវាចឹងទៅណាយើងមិនបាននេះអី បើប្រទេសកើតកលយុថចឹងទៅមានបានរៀនអីអត់ កាលៈទេសៈបង្ខំឲ្យយើងធ្វើអ្វីផ្សេង មិនបានទៅរៀន។

ក៖ អញ្ចឹងទាក់ទងជាមួយចំណាង់ចំណូលចិត្តអ៊ុំម្តង តើអ៊ុំចូលចិត្តពិសារម្ហូបអ្វីជាងគេដែរអ៊ុំ?

ខ៖ ម្ហូបអ្វីក៏ចូលចិត្តដែរគ្រប់តែមុខទាំងអស់ណឹងឲ្យតែមានសាច់ ពីក្មេងទេណឹងដល់ឥឡូវចាស់ទៅវាសូវចង់ប៉ុន្មានទេរឿងសាច់អី។

ក៖ ចុះអ៊ុំចូលចិត្តស្តាប់បទចម្រៀងទេអ៊ុំតាំងពីក្មេងមក?

ខ៖ ពីក្មេងចូលចិត្តតើស្តាប់ កាលពីដើមពីជំនាន់អ៊ុំវាអត់មាននេះអីទេពីដើម មានតែវិទ្យុមួយណឹងម៉ាភូមិស្តាប់គ្នាម៉ាភូមិណា

ក៖ ចុះអ៊ុំចេះលេងឧបករណ៍តន្ត្រីអីទេអ៊ុំ?

ខ៖ អត់ចេះ។

កៈ ចុះនៅក្នុងក្រុមគ្រួសារអ៊ុំមាននរណាចេះលេងភ្លេងទេអ៊ុំ?

ខៈ អត់ទេ សូម្បីតែរាំវ៉ងដើររាំលេងណឹងអត់ដែលមានទេ នៅជំនាន់អ៊ុំមានតែអ៊ុំណឹងឯង។

កៈ តាំងពីក្មេងមកអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយណាជាងគេ?

ខៈ ពីក្មេងមកវាភ្លេចហើយរឿងលេងពីដើមវាមានបោះឈូង បោះអង្គុញអីចឹងណាខែចូលឆ្នាំណានៅវត្តនៅអី។

កៈ អ៊ុំចូលចិត្តលេងកីឡាអ្វីខ្លះដែរអ៊ុំកាលពីក្មេងមក?

ខៈ កីឡានោះបើនិយាយទៅរឿងកីឡាវាមិនសូវបានលេងផង ព្រោះបើយើងនៅក្នុងសាលារៀនលេងតែបាល់បោះ លេងតែបាល់ទះអីណឹងឯងអ៊ុំ។

កៈ មកដល់សព្វថ្ងៃនេះអ៊ុំមានកូនចៅប៉ុន្មាននាក់ហើយអ៊ុំ?

ខៈ ឥឡូវមានកូន៣នាក់ ប្រុស ២ ស្រី១ ហើយនិងចៅមាន៥នាក់ ស្រី៤ ប្រុស ១។

កៈ អញ្ចឹងមកដល់ចុងបញ្ចប់នេះតើអ៊ុំមានអ្វីចង់ផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយរបស់អ៊ុំទេអ៊ុំ? ថាពួកគាត់ណឹងគួរតែធ្វើជាមនុស្សបែបណា ឬក៏អ៊ុំមានអ្វីចង់ផ្តាំផ្ញើរបង្រៀនពួកគាត់ចឹងអ៊ុំ?

ខៈ មាន មានហើយឲ្យកូនចៅទាំងអស់ណឹងខំប្រឹងរៀនសូត្រ ធ្វើតែអំពើល្អ តែមនុស្សយើងធ្វើអំពើល្អហើយយើងបានល្អហើយ យើងធ្វើតែកុសល អកុសលយើងកុំទទួលយកអកុសលហើយកន្លែងណាដែលយើងត្រូវជៀសវាងយើងជៀសវាងទៅ។

កៈ មានអ្វីទៀតទេអ៊ុំ?

ខៈ អត់ទេ។

កៈ បាទអញ្ចឹងខ្ញុំសូមអរគុណអ៊ុំដែលបានអនុញ្ញាតឲ្យខ្ញុំសម្ភាសន៍ ដែលបានចំណាយពេលដើម្បីឲ្យខ្ញុំសម្ភាសន៍អ៊ុំ ហើយខ្ញុំសូមជូនពរឲ្យអ៊ុំមានសុខភាពនិងមានសុភមង្គលក្នុងក្រុមគ្រួសារណាអ៊ុំណា។

ខៈ សាធុ សាធុ ក្មួយ។

កៈ បាទអ៊ុំ៕